ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ករណីជាសះស្បើយ ចំនួន ០១នាក់ និងមិនមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី
# នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២១

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖** គិតត្រឹមម៉ោង ០៧:០០នាទីព្រឹក នៃថ្ងៃទី១៨ ខែមករា ឆ្នាំ ២០២១ មានដូចតារាងខាងក្រោមនេះ ៖

| ល.រ. | បរិយាយ | សរុប (នាក់) | ស្រី (នាក់) | ប្រុស (នាក់) | ផ្សេងៗ |
|---|---|---|---|---|---|
| ១. | **អ្នកមានវីរុសកូវីដ-១៩ ៖** | | | | |
| | ១.១. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៣៧០ | ៩១ | ២៧៩ | អ្នកឆ្លងថ្មី៖ ០នាក់ |
| | ១.២. ពលករធ្វើដំណើរមកពីប្រទេសថៃ | ៦៩ | ៥៤ | ១៥ | អ្នកឆ្លងថ្មី៖ ០នាក់ |
| | **សរុបអ្នកមានវីរុសកូវីដ-១៩** | **៤៣៩** | **១៤៥** | **២៩៤** | អ្នកឆ្លងថ្មី៖ ០នាក់ |
| ២. | **អ្នកព្យាបាលជាសះស្បើយ ៖** | | | | |
| | ២.១. អ្នកដំណើរចូលមកកម្ពុជា និងអ្នកឆ្លងបន្តនៅក្នុងប្រទេស | ៣៦៤ | ៨៨ | ២៧៦ | អ្នកជាសះស្បើយថ្មី៖០នាក់ |
| | ២.២. ពលករធ្វើដំណើរមកពីប្រទេសថៃ | ២២ | ២០ | ០២ | អ្នកជាសះស្បើយថ្មី៖**០១នាក់** |
| | **សរុបអ្នកព្យាបាលជាសះស្បើយ** | **៣៨៦** | **១០៨** | **២៧៨** | អ្នកជាសះស្បើយថ្មី៖**០១នាក់** |
| ៣. | **អ្នកកំពុងសម្រាកព្យាបាល ៖** | | | | |
| | ៣.១.មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន | ០៦ | ០៣ | ០៣ | |
| | ៣.២. មន្ទីរពេទ្យបង្អែក ខេត្តប៉ៃលិន | ០១ | ០១ | ០ | |
| | ៣.៣.មន្ទីរពេទ្យបង្អែក ខេត្តបន្ទាយមានជ័យ | ៣៣ | ២៤ | ០៩ | |
| | ៣.៤. មន្ទីរពេទ្យបង្អែក ខេត្តបាត់ដំបង | ១១ | ០៨ | ០៣ | |
| | ៣.៥.មន្ទីរពេទ្យបង្អែក ខេត្តឧត្តរមានជ័យ | ០២ | ០១ | ០១ | |
| | **សរុបអ្នកកំពុងសម្រាកព្យាបាល** | **៥៣** | **៣៧** | **១៦** | |


ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

**២. ព័ត៌មានប្រចាំថ្ងៃទី១៧ ខែមករា ឆ្នាំ២០២១**

**ក. មានករណីជាសះស្បើយ៖ សរុបចំនួន ០១នាក់ ដែលជាពលករធ្វើដំណើរមកពីប្រទេសថៃ**

- ស្ត្រីជនជាតិខ្មែរ អាយុ ២៨ឆ្នាំ មានអាសយដ្ឋានស្នាក់នៅភូមិដំបូកខ្ពស់ ឃុំអូរដំបង២ ស្រុកសង្កែ ខេត្តបាត់ដំបង បានធ្វើដំណើរមកពីប្រទេសថៃ មកដល់កម្ពុជានៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២១ ត្រូវបានព្យាបាលជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន០២លើក ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យបង្អែកខេត្តបន្ទាយមានជ័យ។

**ខ. មិនមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ៖** នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២១

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្រុមគ្រូពេទ្យស្ម័គ្រចិត្ត **សម្តេចតេជោ ធីតា** អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លងសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងមន្ទីរពិសោធន៍នៃមន្ទីរពេទ្យខេត្តសៀមរាប ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃចន្ទ ៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២១



ទីស្តីការក្រសួងសុខាភិបាលដីឡូត៍លេខ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារៈ (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩